ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

អគ្គលេខាធិការដ្ឋាន

លេខ: ៤០ /២០១៧ អ.កបធ.សជណ

# សេចក្តីប្រកាសព័ត៌មាន

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ មានកិត្តិយសសូមជម្រាបជូនសាធារណជនជ្រាបថា នៅថ្ងៃអង្គារ ទី២៥ ខែកក្កដា ឆ្នាំ២០១៧ ចាប់ពីម៉ោង ១០:០០ ព្រឹក នៅសាលប្រជុំអគារ" ស" វិមានរដ្ឋចំការមន ក្រុមប្រឹក្សាធម្មនុញ្ញបានបើកកិច្ចប្រជុំពេញអង្គ ដើម្បីពិនិត្យនិងសម្រេចលើសំណើលេខ២៤៦ រ.ស ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៧ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភាស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ។

កិច្ចប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញបានសម្រេចជាឯកច្ឆន្ទចេញសេចក្តីសម្រេចលេខ១៨៧/០២៧/២០១៧កបធ.ច ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមសាធារណជនជ្រាប។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧